មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

លក្ខខណ្ឌការងារ

| | |
|---|---|
| **តួនាទី** | *អ្នកហាត់ការផ្នែកកម្មវិធីវិទ្យុ* |
| **រាយការណ៍ជូន** | *អ្នកសម្របសម្រួលកម្មវិធីវិទ្យុ និង ក្រុមការងារវិទ្យុ* |
| **ទីតាំងការងារ** | *មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលមានការិយាល័យនៅរាជធានីភ្នំពេញ នឹងធ្វើដំណើរទៅតាមខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា អាស្រ័យតាមតម្រូវការការងារជាក់ស្តែង។* |
| **រយៈពេល** | *០៦ ខែ* |

## សង្ខេបការងារ

អ្នកហាត់ការពេញម៉ោងផ្នែកកម្មវិធីវិទ្យុមានការងារចំបងគឺក្នុងការគាំទ្រការងារផ្នែកបច្ចេកទេស និងការងាររដ្ឋបាលដល់កម្មវិធីវិទ្យុដើម្បីឲ្យប្រតិបត្តិការការងារបន្ទប់ផ្សាយ និងកម្មវិធីវិទ្យុទាំងមូលប្រព្រឹត្តទៅដោយរលូន។

## ទំនួលខុសត្រូវការងារ

- ជួយការងារបច្ចេកទេសម៉ាស៊ីនផ្សាយ និងជួយការងារទូទៅសម្រាប់ក្រុមការងារ
- ជួយរៀបចំមាតិកាសំឡេងនៃកម្មវិធីវិទ្យុ និងរៀបចំដាក់បញ្ចូលទៅក្នុង OneDrive និងវេបសាយរបស់ម.ស.ម.ក។
- ជួយថតរូបនៅក្នុងកម្មវិធីផ្សេងៗរបស់ម.ស.ម.ក
- កាត់តសំឡេងកម្មវិធីវិទ្យុ និងរចនាគំរូផ្ទាំងសម្រាប់ផ្សព្វផ្សាយកម្មវិធីវិទ្យុ
- ជួយក្នុងការសម្របសម្រួលក្នុងកម្មវិធីវិទ្យុបើមានតម្រូវការ។

## លក្ខខណ្ឌដែលត្រូវជ្រើសរើស

- ជានិស្សិតទើបបញ្ចប់ថ្នាក់បរិញ្ញាបត្រ ឬជានិស្សិតកំពុងសិក្សាឆ្នាំទី៣-៤ ក្នុងវិស័យផ្នែកទំនាក់ទំនងសារព័ត៌មាន ច្បាប់ និងកិច្ចការសាធារណៈ អក្សរសាស្ត្រ និងមនុស្សសាស្ត្រ និងវិស័យនានាដែលពាក់ព័ន្ធ
- មានចំណេះដឹងល្អផ្នែកភាសាអង់គ្លេស (ការសរសេរ និងការនិយាយ)
- មានចំណាប់អារម្មណ៍លើផ្នែកសម្របសម្រួលកម្មវិធីវិទ្យុ និងបច្ចេកវិទ្យាការងារវិទ្យុ
- មានចំណេះដឹងផ្នែកភាសាខ្មែរច្បាស់លាស់(ការសរសេរ)
- មានជំនាញក្នុងការទំនាក់ទំនង និងបុគ្គលិកលក្ខណៈល្អ
- មានចំណេះដឹងផ្នែកកុំព្យូទ័រដូចជា Microsoft Word, Microsoft Excel, E-mail Adobe Photoshop
- មានភាពស្មោះត្រង់ ឧស្សាហ៍ក្នុងការងារ និងមានឆន្ទៈរៀនសូត្រពីការងារដើម្បីអភិវឌ្ឍន៍ខ្លួន

- ពុំចាំបាច់មានបទពិសោធន៍ការងារពីមុន៕

**----ចប់---**